# ទំនុកដំកើង ១៩

ការបង្កើតរបស់ព្រះ

¹ ផ្ទៃមេឃ សំដែងពី សិរីល្អនៃព្រះ
ហើយលំហអាកាស ក៏បង្ហាញ ការដែលព្រះហស្តទ្រង់ធ្វើ

² ថ្ងៃ១ ពោលប្រាប់តដល់ ថ្ងៃ១ទៀត
ហើយយប់១ ក៏សំដែងចំណេះដល់ យប់១ទៀតដែរ
³ ឯពាក្យសំដី ឬភាសា នោះគ្មានឮឡើយ
គ្មានអ្នកណាដែល ឮសំឡេងនៃរបស់ទាំងនោះទេ

⁴ ប៉ុន្តែដំណឹងដែលរបស់ទាំងនោះ ផ្សាយមក
ក៏បានចេញទៅគ្រប់លើផែនដី
ហើយសេចក្តីនោះ បានឮទៅដល់ទីបំផុតលោកីយ៍

នៅលើមេឃ ទ្រង់បានដំឡើងត្រសាលសំរាប់ព្រះអាទិត្យ
⁵ ដែលទុកជាប្តីថ្មោងថ្មី កំពុងតែចេញពីបន្ទប់ដេក
ទាំងមានសេចក្តីអំណរនឹងរត់តាមផ្លូវខ្លួន
ដូចជាមនុស្សខ្លាំងពូកែ
⁶ ព្រះអាទិត្យ ក៏រះពីជើងមេឃម្ខាង
ហើយដើរវង់ទៅដល់ជើងមេឃម្ខាង
គ្មានរបស់អ្វីលាក់កំបាំងពីកំដៅនៃព្រះអាទិត្យទេ។

## ក្រឹត្យវិន័យរបស់ព្រះ

៧ ឯក្រឹត្យវិន័យរបស់ព្រះយេហូវ៉ា នោះគ្រប់លក្ខណ៍
ក៏កែព្រលឹងឡើងវិញ
សេចក្តីបន្ទាល់នៃព្រះយេហូវ៉ា ជាពិត
ក៏ធ្វើឲ្យមនុស្សខ្លៅល្ងង់មានប្រាជ្ញា
៨ សេចក្តីបញ្ញត្តរបស់ព្រះយេហូវ៉ា សុទ្ធតែទៀងត្រង់
ក៏បណ្តាលឲ្យចិត្តរីករាយសប្បាយ
ក្រឹត្យក្រមនៃព្រះយេហូវ៉ា ជាសុទ្ធសាធ ក៏បំភ្លឺភ្នែក
៩ សេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា នោះជាបរិសុទ្ធ
ក៏នៅជាប់ជារៀងរាបដរាប
អស់ទាំងខច្បាប់របស់ព្រះយេហូវ៉ា សុទ្ធតែពិតត្រង់
ហើយសុចរិតគ្រប់ជំពូក
១០ សេចក្តីទាំងនោះ គួរចង់បានលើសជាងមាស
អើ ជាជាងមាសសុទ្ធជាច្រើនផង
ក៏ផ្អែមជាងទឹកឃ្មុំ ហើយជាងដំណក់ស្រក់
ពីសំណុះផង

ការឆ្លើយតបចំពោះក្រិត្យវិន័យរបស់ព្រះ

១១ មួយទៀត ទូលបង្គំ ជាអ្នកបំរើទ្រង់
ក៏ចេះប្រយ័ត្ន ដោយសារសេចក្ដីទាំងនោះដែរ
ហើយដែលកាន់តាម

នោះក៏មានរង្វាន់យ៉ាងធំ

១២ តើអ្នកណា នឹងស្គាល់អំពើខុសឆ្គងរបស់ខ្លួនបាន

សូមជំរះទូលបង្គំឲ្យជ្រះស្អាតពីអំពើលាក់កំបាំងផង
១៣ សូមរាំងរាទូលបង្គំ ជាអ្នកបំរើទ្រង់
ឲ្យរួចពីបាបដែលធ្វើដោយល្មើសដែរ
កុំឲ្យបាបនោះមានអំណាចលើទូលបង្គំឡើយ

នោះទូលបង្គំនឹងបានទៀងត្រង់
ហើយនឹងបានរួចពីអំពើរំលងយ៉ាងធំផង

១៤ ឱព្រះយេហូវ៉ា ជាថ្មដា
ហើយជាអ្នកប្រោសលោះនៃទូលបង្គំអើយ
សូមឲ្យពាក្យសំដីដែលចេញមកពីមាត់ទូលបង្គំ
និងការរំពឹងគិតក្នុងចិត្តរបស់ទូលបង្គំ

បានគួរគាប់នៅព្រះនេត្រទ្រង់។